ឯកសារសម្រាប់កិច្ចប្រជុំ
ថ្ងៃទី..០៤...ខែ..កញ្ញា...ឆ្នាំ..២០១៧..

*សេចក្តីព្រាងដំបូង*

# សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# នីតិវិធីជម្រះក្តីវិវាទការងារ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧**

# មាតិកា


ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ 1

មាត្រា១ ........ 1

មាត្រា២ ........ 1

មាត្រា៣ ........ 1

មាត្រា៤ ........ 1

ជំពូកទី២ ការដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន ........ 2

មាត្រា៥ ........ 2

មាត្រា៦ ........ 2

មាត្រា៧ ........ 2

មាត្រា៨ ........ 2

មាត្រា៩ ........ 2

ជំពូកទី៣ ការដោះស្រាយវិវាទការងារនៅថ្នាក់ក្រសួង ........ 3

ផ្នែកទី១ នីតិវិធីនៃការដោះស្រាយវិវាទបុគ្គល ........ 3

មាត្រា១០ ........ 3

មាត្រា១១ ........ 3

មាត្រា១២ ........ 3

មាត្រា១៣ ........ 3

មាត្រា១៤ ........ 4

មាត្រា១៥ ........ 4

ផ្នែកទី២ នីតិវិធីនៃការដោះស្រាយវិវាទការងាររួម ........ 4

មាត្រា១៦ ........ 4

មាត្រា១៧ ........ 4

មាត្រា១៨ ........ 4

មាត្រា១៩ ........ 5

មាត្រា២០ ........ 5

មាត្រា២១ ........ 5

ជំពូកទី៤ ការដោះស្រាយវិវាទការងារដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល ........ 5

ផ្នែកទី១ នីតិវិធីដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ........ 5

មាត្រា២២ ........ 5

មាត្រា២៣ ........ 6

មាត្រា២៤ ........ 6

មាត្រា២៥ ........ 6

មាត្រា២៦ ....... 6
មាត្រា២៧ ....... 7
មាត្រា២៨ ....... 7
មាត្រា២៩ ....... 7
មាត្រា៣០ ....... 7
មាត្រា៣១ ....... 8
មាត្រា៣២ ....... 8
**ផ្នែកទី២ សេចក្តីបង្គាប់អាជ្ញាកណ្តាល** ....... 9
មាត្រា៣៣ ....... 9
មាត្រា៣៤ ....... 9
មាត្រា៣៥ ....... 10
មាត្រា៣៦ ....... 10
**ជំពូកទី៥ ការជំនុំជម្រះបណ្តឹងការងារដោយតុលាការការងារ ....... 11**
មាត្រា៣៧ ....... 11
**ជំពូកទី៦ វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ ....... 11**
មាត្រា៣៨ ....... 11
មាត្រា៣៩ ....... 11
មាត្រា៤០ ....... 11
មាត្រា៤១ ....... 11
មាត្រា៤២ ....... 11
**ជំពូកទី៧ អន្តរប្បញ្ញត្តិ ....... 11**
មាត្រា៤៣ ....... 11
**ជំពូកទី៨ អវសានប្បញ្ញត្តិ ....... 12**
មាត្រា៤៤ ....... 12
មាត្រា៤៥ ....... 12

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណង៖

- ធានាដំណើរការដោះស្រាយវិវាទការងារប្រកបដោយយុត្តិធម៌ តម្លាភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស

- ធានាក្នុងការផ្តល់យុត្តិធម៌លើបណ្តឹងការងារគ្រប់ប្រភេទ ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

- ធានាសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ បរិយាកាសល្អសម្រាប់ការវិនិយោគ និងបង្កើតការងារ។

**មាត្រា២ .-**

ច្បាប់នេះមានគោលដៅ៖

- បង្កើតនីតិវិធីដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន ការដោះស្រាយវិវាទការងារដោយក្រសួងទទួលបន្ទុកវិស័យការងារ និងការដោះស្រាយវិវាទការងារដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល

- បង្កើតនីតិវិធីការងារសម្រាប់ដោះស្រាយបណ្តឹងការងារគ្រប់ប្រភេទ ដោយប្រព័ន្ធយុត្តាធិការការងារ។

**មាត្រា៣ .-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើវិវាទនិងបណ្តឹងទាំងឡាយក្នុងវិស័យការងារ។

**មាត្រា៤ .-**

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

- **វិវាទការងារ** សំដៅដល់វិវាទអំពីសិទ្ធិឬវិវាទអំពីផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងការងាររវាងកម្មករនិយោជិតនិងនិយោជក ហើយវិវាទនេះអាចជាវិវាទបុគ្គលឬវិវាទការងាររួម។

- **វិវាទបុគ្គល** សំដៅដល់វិវាទដែលកើតមានឡើងរវាងនិយោជកនិងកម្មករនិយោជិតម្នាក់ឬច្រើននាក់ ឬអ្នករៀនធ្វើការម្នាក់ឬច្រើននាក់ តាមរឿងរៀងៗខ្លួន ហើយទាក់ទងនឹងការបកស្រាយឬការអនុវត្តបទប្បញ្ញត្តិនៃកិច្ចសន្យាការងារ ឬកិច្ចសន្យាហ្វឹកហ្វឺនកម្មករនិយោជិត ឬបទប្បញ្ញត្តិការងារនៃអនុសញ្ញារួមព្រមទាំងច្បាប់ជាធរមាន។

- **វិវាទការងាររួម** សំដៅដល់វិវាទដែលកើតឡើងរវាងនិយោជកម្នាក់ឬច្រើននាក់ និងកម្មករនិយោជិតរបស់ខ្លួនមួយចំនួនអំពីរឿងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឲ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយវិវាទនេះអាចបណ្តាលឲ្យប៉ះពាល់ដល់ដំណើរការជាប្រក្រតីនៃសហគ្រាសឬធ្វើឱ្យខូចសន្តិភាពសង្គម។

- **វិវាទអំពីសិទ្ធិ** សំដៅដល់វិវាទដែលទាក់ទងនឹងសិទ្ធិស្របច្បាប់របស់កម្មករនិយោជិតនិងនិយោជកដែលមានបញ្ញត្តក្នុងច្បាប់ លិខិតបទដ្ឋាន កិច្ចសន្យាការងារ ឬអនុសញ្ញារួមជាដើម។

- វិវាទអំពីផលប្រយោជន៍ សំដៅដល់វិវាទដែលទាក់ទងនឹងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិតនិងនិយោជកដែលមិនមានបញ្ញត្តនៅក្នុងច្បាប់ លិខិតបទដ្ឋាន កិច្ចសន្យាការងារ ឬអនុសញ្ញារួម។

- បណ្តឹងការងារ សំដៅដល់បណ្តឹងដែលកើតឡើងពីវិវាទការងារ ឬពីការអនុវត្តច្បាប់ និងបទដ្ឋានការងារ។

- កូដកម្ម សំដៅដល់ការឈប់ធ្វើការងារដោយកម្មករនិយោជិតមួយក្រុម ដែលមានការព្រមព្រៀងគ្នាហើយបានធ្វើឡើងនៅក្នុងសហគ្រាសមួយ ឬគ្រឹះស្ថានមួយក្នុងគោលបំណងដើម្បីទទួលបាននូវដំណោះស្រាយដ៏យុត្តិធម៌ ចំពោះការទាមទាររបស់កម្មករនិយោជិត ពីនិយោជកហើយក៏ជាលក្ខខណ្ឌដើម្បីចូលធ្វើការវិញ។

- ឡុកអៅ សំដៅដល់ការបិទសហគ្រាសឬគ្រឹះស្ថានទាំងមូលឬមួយផ្នែក ដោយនិយោជកក្នុងឱកាសដែលមានវិវាទការងារ។

## ជំពូកទី២
## ការដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន

### មាត្រា៥ .-

មុននឹងប្តឹងទៅមន្ត្រីផ្សះផ្សា គ្រប់វិវាទការងារទាំងឡាយត្រូវធ្វើការដោះស្រាយឲ្យអស់លទ្ធភាពជាមុនសិននៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន។

និយោជកត្រូវរៀបចំឲ្យមានការដោះស្រាយវិវាទការងារយ៉ាងយូរក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានវិវាទកើតឡើង។

### មាត្រា៦ .-

នៅរាល់ពេលបញ្ចប់ការដោះស្រាយវិវាទការងារ ភាគីវិវាទត្រូវធ្វើកំណត់ហេតុរួមអំពីលទ្ធផលនៃការដោះស្រាយ ដោយមានបញ្ជាក់ច្បាស់លាស់ពីការព្រមព្រៀងឬមិនព្រមព្រៀងគ្នាលើចំណុចណាមួយនៃវិវាទ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយភាគីវិវាទ។

### មាត្រា៧ .-

ភាគីវិវាទត្រូវដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន ដោយគោរពនូវគោលការណ៍សុចរិត ស្មោះត្រង់ សន្តិវិធី និងដោយភាពយោគយល់គ្នា។

### មាត្រា៨ .-

ក្រោយពីបញ្ចប់នីតិវិធីដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន ភាគីវិវាទអាចប្តឹងមកមន្ត្រីផ្សះផ្សា ដើម្បីដោះស្រាយបន្តលើចំណុចវិវាទដែលភាគីមិនព្រមព្រៀងគ្នា។

### មាត្រា៩ .-

ភាគីវិវាទមានសិទ្ធិជ្រើសតាំងអ្នកតំណាងក្នុងការដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន និងនៅថ្នាក់ក្រសួង។

អ្នកតំណាងភាគីវិវាទត្រូវតែជាបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ជាធរមាន។

## ជំពូកទី៣
## ការដោះស្រាយវិវាទការងារនៅថ្នាក់ក្រសួង
### ផ្នែកទី១
### នីតិវិធីនៃការដោះស្រាយវិវាទបុគ្គល

**មាត្រា១០ .-**

ក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលបណ្តឹងពីភាគីណាមួយ មន្ត្រីផ្សះផ្សា ត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់នៃវិវាទ ឲ្យមកផ្តល់ព័ត៌មាន និងឯកសារជាភស្តុតាងនានា ដើម្បីជាមូលដ្ឋានក្នុងការផ្សះផ្សាវិវាទ។

ការសាកសួរព័ត៌មានត្រូវធ្វើដាច់ដោយឡែកពីគ្នា។ គ្រប់ពេលសាកសួរព័ត៌មាន មន្ត្រីផ្សះផ្សា ត្រូវធ្វើកំណត់ហេតុ ដោយមានចុះហត្ថលេខាមន្ត្រីផ្សះផ្សា និងភាគីដែលផ្តល់ព័ត៌មាន ហើយត្រូវផ្តល់កំណត់ហេតុនេះជូនភាគីដែលផ្តល់ព័ត៌មាន ១(មួយ)ច្បាប់។

**មាត្រា១១ .-**

ភាគីនៃវិវាទបុគ្គលឬអ្នកតំណាងនៃជននោះត្រូវចូលមកផ្តល់ព័ត៌មាន តាមការកោះអញ្ជើញរបស់មន្ត្រីផ្សះផ្សា។

ក្នុងករណីដើមបណ្តឹងឬអ្នកតំណាងនៃជននោះមិនមកផ្តល់ព័ត៌មានជូនមន្ត្រីផ្សះផ្សា តាមកាលកំណត់ ឬក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីថ្ងៃកំណត់ ដោយគ្មានមូលហេតុសមស្រប ពាក្យប្តឹងនោះត្រូវចាត់ទុកជាមោឃៈ។

ក្នុងករណីចុងចម្លើយឬអ្នកតំណាងនៃជននោះមិនបង្ហាញខ្លួនតាមកាលកំណត់ ឬក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីថ្ងៃកំណត់ ដោយគ្មានមូលហេតុសមស្រប វិវាទត្រូវចាត់ទុកថាមិនសះជា ហើយចុងចម្លើយត្រូវចាត់ទុកថាមានកំហុសដូចការចោទប្រកាន់របស់ដើមបណ្តឹងទាំងស្រុង។

**មាត្រា១២ .-**

បន្ទាប់ពីការសាកសួរនិងប្រមូលព័ត៌មាននិងឯកសារនានាហើយ មន្ត្រីផ្សះផ្សា ត្រូវធ្វើលិខិតអញ្ជើញភាគីទាំងសងខាងមកធ្វើការផ្សះផ្សា ដោយយកច្បាប់ បទបញ្ញា អនុសញ្ញារួម ឬកិច្ចសន្យាការងារ ជាមូលដ្ឋាន។

មន្ត្រីផ្សះផ្សាត្រូវធ្វើការផ្សះផ្សាវិវាទបុគ្គល ក្នុងរយៈពេល ៣(បី)សប្តាហ៍យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យប្តឹង។

**មាត្រា១៣ .-**

មន្ត្រីផ្សះផ្សាត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សា ដោយមានបញ្ជាក់ច្បាស់លាស់ពីចំណុចសះជាឬមិនសះជា។ កំណត់ហេតុនោះត្រូវចុះហត្ថលេខាដោយមន្ត្រីផ្សះផ្សា និងភាគីវិវាទទាំងសងខាង ហើយត្រូវចម្លងជូនភាគីវិវាទ។

**មាត្រា១៤ .-**

ការព្រមព្រៀងដែលបានធ្វើនៅចំពោះមុខមន្ត្រីផ្សះផ្សា គឺជាការព្រមព្រៀងយកជាបានការចំពោះមុខច្បាប់។

**មាត្រា១៥ .-**

ក្នុងករណីមិនសះជា មន្ត្រីផ្សះផ្សាត្រូវជម្រាបទៅភាគី អំពីសិទ្ធិរបស់សាមីភាគីដែលអាចធ្វើពាក្យប្តឹងជាបន្តទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

មន្ត្រីផ្សះផ្សាត្រូវធ្វើរបាយការណ៍ស្តីពីការផ្សះផ្សាវិវាទបុគ្គលដែលមិនសះជា ទុកជូនភាគីវិវាទបុគ្គល ជាឯកសារយោងដើម្បីប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

## ផ្នែកទី២
## នីតិវិធីនៃការដោះស្រាយវិវាទការងាររួម

**មាត្រា១៦ .-**

វិវាទការងាររួមត្រូវដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទការងារ ដូចមានចែងនៅក្នុងអនុសញ្ញារួម។

ក្នុងករណីដែលអនុសញ្ញារួមមិនមានចែងអំពីនីតិវិធីដោះស្រាយវិវាទការងារ ឬក្នុងករណីដែលសហគ្រាសឬគ្រឹះស្ថានមិនមានអនុសញ្ញារួម ភាគីវិវាទត្រូវជូនដំណឹងអំពីវិវាទការងាររួមទៅមន្ត្រីផ្សះផ្សា ដើម្បីធ្វើការផ្សះផ្សាទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ។

**មាត្រា១៧ .-**

មានតែសហជីពដែលមានភាពជាតំណាងបំផុត ទើបមានសិទ្ធិផ្តាច់មុខក្នុងការតំណាងឲ្យកម្មករនិយោជិតទាំងអស់ ដើម្បីធ្វើការដោះស្រាយវិវាទការងាររួមជាមួយនិយោជក ឬសមាគមនិយោជកនៅតាមថ្នាក់សហគ្រាសឬគ្រឹះស្ថាន ឬនៅថ្នាក់វិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យ។

ក្នុងករណីមិនមានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួមត្រូវអនុវត្តតាមរយៈក្រុមប្រឹក្សាចរចា។

ក្នុងករណីនៅក្នុងសហគ្រាសឬគ្រឹះស្ថានមិនទាន់មានសហជីព មន្ត្រីផ្សះផ្សាមានកាតព្វកិច្ចចាត់តាំងអ្នកតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម។

**មាត្រា១៨ .-**

ក្រោយពីបញ្ចប់នីតិវិធីដោះស្រាយនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន ភាគីវិវាទការងាររួមត្រូវប្តឹងមកមន្ត្រីផ្សះផ្សា ដើម្បីដោះស្រាយបន្តលើចំណុចវិវាទដែលភាគីមិនព្រមព្រៀងគ្នា។

ក្រោយពីទទួលពាក្យបណ្តឹង មន្ត្រីផ្សះផ្សាត្រូវចាប់ផ្តើមអនុវត្តតាមនីតិវិធីផ្សះផ្សា ក្នុងរយៈពេល ៤៨(សែសិបប្រាំបី)ម៉ោង។

ភាគីត្រូវតែចូលរួមប្រជុំផ្តល់ព័ត៌មានតាមការអញ្ជើញរបស់មន្ត្រីផ្សះផ្សា។ ក្នុងករណីភាគីវិវាទណាមួយមិនចូលរួមប្រជុំទេ នោះមន្ត្រីផ្សះផ្សាត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

នៅពេលកំពុងប្រជុំផ្សះផ្សាភាគីវិវាទមិនត្រូវដើរចេញមុនចប់កិច្ចប្រជុំឡើយ។

**មាត្រា១៩ .-**

ការព្រមព្រៀងសះជាដែលបានចុះហត្ថលេខាដោយភាគី និងបានចុះហត្ថលេខាដោយមន្ត្រីផ្សះផ្សា មានតម្លៃនិងអានុភាពដូចគ្នានឹងអនុសញ្ញារួមរវាងភាគី។

មន្ត្រីផ្សះផ្សាត្រូវធ្វើរបាយការណ៍សះជាជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការក្រោយពេលបញ្ចប់ការផ្សះផ្សា។

**មាត្រា២០ .-**

បើគ្មានការព្រមព្រៀងទេ មន្ត្រីផ្សះផ្សាត្រូវកត់ត្រាបញ្ជាក់នូវចំណុចទាំងឡាយដែលការផ្សះផ្សាមិនសះជា ហើយត្រូវសរសេររបាយការណ៍អំពីវិវាទនោះ។

មន្ត្រីផ្សះផ្សាត្រូវបញ្ជូនសំណុំលិខិតទាំងនោះ ជូនទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារយ៉ាងយូរបំផុតក្នុងរយៈពេល៤៨(សែសិបប្រាំបី)ម៉ោង ក្រោយពេលបញ្ចប់ការផ្សះផ្សា។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារត្រូវបញ្ជូនសំណុំរឿងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល យ៉ាងយូរបំផុតក្នុងរយៈពេល៣(បី)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលទទួលបានសំណុំលិខិតពីមន្ត្រីផ្សះផ្សា។

**មាត្រា២១ .-**

ចំពោះវិវាទការងាររួមដែលភាគីពុំបានប្តឹងឬជូនដំណឹងមកមន្ត្រីផ្សះផ្សា ឬវិវាទការងាររួមណាដែលមានការប៉ះពាល់ឬអាចបណ្តាលឲ្យប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារត្រូវចាត់តាំងមន្ត្រីផ្សះផ្សា ដើម្បីធ្វើការផ្សះផ្សាភ្លាមៗ ចុះសាកសួរព័ត៌មាន និងធ្វើការផ្សះផ្សាដល់ទីកន្លែង។

ក្នុងករណីនេះ ការដោះស្រាយត្រូវអនុវត្តដូចករណីដែលមានបណ្តឹង ឬការជូនដំណឹងមកមន្ត្រីផ្សះផ្សា។

## ជំពូកទី៤

## ការដោះស្រាយវិវាទការងារដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល

### ផ្នែកទី១

### នីតិវិធីដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល

**មាត្រា២២ .-**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទបុគ្គលនិងវិវាទការងាររួមបន្ទាប់ពីការផ្សះផ្សាវិវាទការងារនោះពុំបានសះជានៅដំណាក់កាលផ្សះផ្សារបស់ក្រសួងទទួលបន្ទុកវិស័យការងារ។

កថាខណ្ឌទី១នៃមាត្រានេះ មិនជំទាស់ទៅនឹងនីតិវិធីដែលមានចែងក្នុងអនុសញ្ញារួមអំពីអាជ្ញាកណ្តាល ប្រសិនបើមាន ឬនីតិវិធីណាមួយផ្សេងទៀតដែលមានការយល់ព្រមពីភាគីទាំងអស់នៃវិវាទ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចត្រូវបានបង្កើតឡើងនៅតាមតំបន់ឬខេត្តមួយចំនួនតាមការចាំបាច់។ ក្នុងករណីដែលមិនទាន់មានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅតាមតំបន់ឬខេត្ត វិវាទការងារទាំងឡាយនៃតំបន់ឬខេត្តនោះ ត្រូវដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលរាជធានី។

**មាត្រា២៣ .-**

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានសមាសភាពដូចតទៅ៖

ក- មួយភាគបីស្មើឡើងដោយ ក្រសួងទទួលបន្ទុកវិស័យការងារ

ខ- មួយភាគបីស្មើឡើងដោយ ភាគីនិយោជក ដែលជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ

គ- មួយភាគបីស្មើឡើងដោយ ភាគីសហជីព ដែលជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានលេខាធិការដ្ឋានមួយដែលរ៉ាប់រងដោយក្រសួងទទួលបន្ទុកវិស័យការងារ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

**មាត្រា២៤ .-**

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវធ្វើការរួមប្រជុំជាដាច់ខាតក្នុងរយៈពេល៣(បី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសំណុំរឿងអំពីវិវាទការងារពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ចំពោះវិវាទការងាររួម ឬបន្ទាប់ពីទទួលបានបណ្តឹងពីភាគីវិវាទ ចំពោះវិវាទបុគ្គល។ ការរួមប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវតែប្រព្រឹត្តទៅដោយសម្ងាត់។

**មាត្រា២៥ .-**

រាល់វិវាទការងារទាំងឡាយដែលត្រូវបានបញ្ជូនឬប្តឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវដោះស្រាយដោយក្រុមអាជ្ញាកណ្តាលមួយ ដែលត្រូវបានបង្កើតឡើងសម្រាប់តែការដោះស្រាយវិវាទនោះ។

ក្រុមអាជ្ញាកណ្តាលខាងលើ ត្រូវមានសមាសភាពត្រីភាគី។

**មាត្រា២៦ .-**

វិវាទបុគ្គល ត្រូវដោះស្រាយដោយក្រុមអាជ្ញាកណ្តាលចំនួន៣(បី)រូប ដែលភាគីវិវាទអាចជ្រើសរើសចេញពីបញ្ជីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចខាងក្រោម៖

ក- សមាជិក១(មួយ)រូប ក្នុងបញ្ជីរបស់ភាគីនិយោជក ហើយដែលត្រូវបានជ្រើសរើសដោយនិយោជក ឬតំណាងនិយោជកដែលជាភាគីវិវាទ

ខ- សមាជិក១(មួយ)រូប ក្នុងបញ្ជីរបស់ភាគីសហជីព ហើយដែលត្រូវបានជ្រើសរើសដោយសហជីព ឬតំណាងកម្មករនិយោជិត ឬកម្មករនិយោជិត ដែលជាភាគីវិវាទ

គ- សមាជិក១(មួយ)រូប ដែលត្រូវធ្វើជាប្រធានក្រុមអាជ្ញាកណ្តាលនេះ ត្រូវជ្រើសរើសក្នុងបញ្ជីរបស់ក្រសួងទទួលបន្ទុកវិស័យការងារ ដោយមានការឯកភាពពីសមាជិកទាំង២(ពីរ)រូបខាងលើ។ ក្នុងករណី ដែលសមាជិកក្រុមអាជ្ញាកណ្តាលទាំង២(ពីរ)រូបនេះ មិនឯកភាពគ្នាក្នុងការជ្រើសរើសសមាជិកទី៣ នោះការជ្រើសរើសត្រូវធ្វើតាមការចាប់ឆ្នោតក្នុងចំណោមសមាសភាពដូចមានចែងក្នុងចំណុច "ក" មាត្រា២៣ នៃច្បាប់នេះ។

**មាត្រា២៧ .–**

ការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចប្រព្រឹត្តទៅ ដោយមានសវនាការចំនួន២(ពីរ)លើក។

សវនាការលើកទី១ ត្រូវមានសមាសភាពអាជ្ញាកណ្ដាល៣(បី)រូប ដូចមានចែងក្នុងមាត្រា២៦ នៃច្បាប់នេះ។

អង្គសវនាការលើកទី២ ត្រូវមានសមាសភាពអាជ្ញាកណ្ដាល៥(ប្រាំ)រូប ដែលភាគីវិវាទអាចជ្រើសរើសចេញពីបញ្ជីក្រុមប្រឹក្សាអាជ្ញាកណ្ដាលដូចខាងក្រោម៖

ក- សមាជិក២(ពីរ)រូប ក្នុងបញ្ជីរបស់ភាគីនិយោជក ហើយត្រូវបានជ្រើសរើសដោយនិយោជក ឬតំណាងនិយោជកដែលជាភាគីវិវាទ

ខ- សមាជិក២(ពីរ)រូប ក្នុងបញ្ជីរបស់ភាគីសហជីព ហើយត្រូវបានជ្រើសរើសដោយសហជីព ឬតំណាងកម្មករនិយោជិត ឬកម្មករនិយោជិតដែលជាភាគីវិវាទ

គ- សមាជិក១(មួយ)រូប ដែលត្រូវធ្វើជាប្រធានក្រុមអាជ្ញាកណ្ដាលនៃអង្គសវនាលើកទី២នេះ ត្រូវជ្រើសរើសក្នុងបញ្ជីរបស់ក្រសួងទទួលបន្ទុកវិស័យការងារ ដោយមានការឯកភាពពីសមាជិកក្រុមអាជ្ញាកណ្ដាលទាំង៤(បួន)រូបខាងលើ។ ក្នុងករណីដែលមិនមានការឯកភាពគ្នា នោះការជ្រើសរើសនេះត្រូវធ្វើតាមការចាប់ឆ្នោតក្នុងចំណោមសមាសភាពដូចមានចែងក្នុងចំណុច "ក" នៃមាត្រា២៣ នៃច្បាប់នេះ។

**មាត្រា២៨ .–**

សវនាការលើកទី២ អាចដំណើរការបាន ដោយតម្រូវឲ្យមានការយល់ព្រមពីគូភាគីវិវាទ។

នីតិវិធីនៃដំណើរការសវនាការលើកទី២ ត្រូវអនុវត្តដូចគ្នានឹងនីតិវិធីនៃដំណើរការនៃសវនាការលើកទី១ លើកលែងតែមានបទប្បញ្ញត្តិពិសេសចែងផ្សេងពីនេះ។

**មាត្រា២៩ .–**

ក្រុមអាជ្ញាកណ្ដាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល និងដាក់ជូននូវឯកសារនិងព័ត៌មានចាំបាច់ផ្សេងៗទៀត។

ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាលដោយផ្ទាល់ខ្លួន ឬអាចតំណាងដោយបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ជាធរមាន។

ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ ប៉ុន្តែមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាលដោយគ្មានមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញជាសេចក្ដីបង្គាប់។

**មាត្រា៣០ .–**

ភាគីវិវាទត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលជាកំណត់។

ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្ដាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទដូចជា កូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឲ្យស្ថានភាពវិវាទ

កាន់តែឆ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្ដាលបានអញ្ជើញឲ្យចូលរួម។

ក្នុងករណីដែលកម្មករនិយោជិតត្រូវបានគេតម្រូវឲ្យចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមអាជ្ញាកណ្ដាលក្នុងពេលម៉ោងធ្វើការ និយោជករបស់កម្មករនិយោជិតទាំងនោះត្រូវតែអនុញ្ញាតឲ្យកម្មករនិយោជិតនោះចូលរួម ដោយមិនឲ្យទទួលផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិការងារទាំងឡាយដែលកម្មករនិយោជិតនោះមានឡើយ។

**មាត្រា៣១ .–**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនមានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃវិវាទការងារនោះតែប៉ុណ្ណោះ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះវិវាទដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ឬអនុសញ្ញារួមណាមួយ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ចំពោះវិវាទឯទៀតទាំងអស់។

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវបំពេញមុខងារដោយឯករាជ្យទាំងស្រុង និងនៅក្នុងរង្វង់នៃអំណាចរបស់ខ្លួន។ គ្មានបុគ្គលណាម្នាក់ត្រូវផ្ដល់ការណែនាំដល់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឬដល់សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលទាក់ទងនឹងការដោះស្រាយវិវាទការងារឡើយ។ សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវតែមានភាពមិនលម្អៀង។

សមាជិកម្នាក់ៗនៃក្រុមអាជ្ញាកណ្ដាលត្រូវបដិសេធខ្លួនឯងពីក្រុមអាជ្ញាកណ្ដាលដែលខ្លួនត្រូវបានគេជ្រើសរើស ប្រសិនកាលៈទេសៈដែលកើតមានឡើងចោទជាមន្ទិលសង្ស័យសមស្របអំពីភាពមិនលម្អៀងឬឯករាជ្យភាពរបស់ខ្លួន រួមមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណបុគ្គលឬអាជីពជាមួយសមាជិកដទៃទៀតនៃក្រុមអាជ្ញាកណ្ដាលឬជាមួយភាគីណាមួយ ឬដោយមានប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍អាជីពផ្ទាល់ពីលទ្ធផលនៃរឿងក្ដីនោះ។ ការដែលសមាជិកនៃក្រុមអាជ្ញាកណ្ដាលណាដែលពុំបដិសេធខ្លួនឯងតាមបទប្បញ្ញត្តិនេះ អាចត្រូវបានយកធ្វើជាហេតុផលសម្រាប់អនុវត្តបញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៣៦នៃច្បាប់នេះ ដែលទាក់ទងនឹងការពុំទទួលស្គាល់សេចក្ដីបង្គាប់។

**មាត្រា៣២ .–**

ចំពោះបញ្ហាដែលបានដាក់ជូនក្រុមអាជ្ញាកណ្ដាល ក្រុមអាជ្ញាកណ្ដាលមានសិទ្ធិនិងអំណាចក្នុងការសម្រេចឲ្យភាគីវិវាទផ្ដល់សំណងយ៉ាងពេញលេញចំពោះរាល់ការបំពានបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់និងបទដ្ឋានការងារផ្សេងៗ អនុសញ្ញារួម ឬក្នុងកាតព្វកិច្ចផ្សេងទៀតដែលកើតចេញពីទំនាក់ទំនងវិជ្ជាជីវៈរវាងនិយោជកនិងកម្មករនិយោជិត។ ក្នុងដែនអនុវត្តនៃច្បាប់និងបទដ្ឋានការងារផ្សេងៗ ក្រុមអាជ្ញាកណ្ដាលមានសិទ្ធិនិងអំណាចក្នុងការសម្រេចឲ្យភាគីវិវាទផ្ដល់នូវសំណងរដ្ឋប្បវេណី ឬសំណងខូចខាតដែលមានលក្ខណៈត្រឹមត្រូវនិងយុត្តិធម៌ដោយរួមទាំង៖

ក- ការបញ្ជាឲ្យទទួលយកកម្មករនិយោជិតដែលបានបណ្ដេញចេញឲ្យចូលមកធ្វើការវិញនៅក្នុងតំណែងចាស់ឬតំណែងសមរម្យណាមួយ

ខ- ការបញ្ជាឲ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់

គ- ការបញ្ជាឲ្យបញ្ឈប់ជាបន្ទាន់នូវកូដកម្មឬឡុកអៅដែលកំពុងធ្វើឡើងដោយភាគីវិវាទ

ឃ- ការបញ្ជាឲ្យបញ្ឈប់ជាបន្ទាន់នូវរាល់ការប្រព្រឹត្តទាំងឡាយណាដែលមិនស្របច្បាប់ឬដែលត្រូវហាមឃាត់ ដោយរួមទាំងអំពើសងសឹកនិងអំពើផ្សេងៗទៀតក្រៅពីអំពើសងសឹក

ង- ការបញ្ជាឲ្យធ្វើការចរចាដើម្បីស្វែងរកដំណោះស្រាយណាមួយជាកំហិត

ច- ការបង្កើតលក្ខខណ្ឌទាំងឡាយណាសម្រាប់អនុសញ្ញារួម

ឆ- ការសងការខូចខាតផ្សេងៗទៀតតាមការសមស្រប។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចជូនដំណឹងអំពីសេចក្តីបង្គាប់របស់ខ្លួនទៅនាយកដ្ឋានទទួលបន្ទុកអធិការកិច្ចការងារឬមន្ទីរទទួលបន្ទុកវិស័យការងាររាជធានី ខេត្ត ដើម្បីជួយចាត់វិធានការក្នុងការអនុវត្តសេចក្តីបង្គាប់នោះ។

## ផ្នែកទី២
## សេចក្តីបង្គាប់អាជ្ញាកណ្តាល

**មាត្រា៣៣ .-**

ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃបានទទួលសំណុំរឿងអំពីវិវាទការងាររួម ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវរាយការណ៍អំពីសេចក្តីបង្គាប់របស់ខ្លួនជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ហើយរដ្ឋមន្ត្រីត្រូវចាត់ការផ្តល់ដំណឹងទៅភាគីវិវាទភ្លាមអំពីសេចក្តីបង្គាប់នោះ ដោយផ្តល់ជូនភាគីទាំងនោះនូវច្បាប់ចម្លងសេចក្តីបង្គាប់ដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន ១(មួយ)ច្បាប់ម្នាក់។

ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលបានបណ្តឹងអំពីវិវាទបុគ្គល ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវជូនដំណឹងអំពីសេចក្តីបង្គាប់របស់ខ្លួនជាលាយលក្ខណ៍អក្សរជូនទៅភាគីវិវាទភ្លាម ដោយផ្តល់ជូនភាគីទាំងនោះនូវច្បាប់ចម្លងសេចក្តីបង្គាប់ដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន ១(មួយ)ច្បាប់ម្នាក់។

ក្នុងករណីដែលដំណើរការនៃសំណុំរឿងត្រូវបានបញ្ចប់ដោយមិនមានសេចក្តីបង្គាប់នោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវជូនដំណឹងអំពីការបញ្ចប់នៃដំណើរការនេះ ទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ និងទៅភាគីវិវាទ។

**មាត្រា៣៤ .-**

ក្នុងរយៈពេល៨(ប្រាំបី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលការជូនដំណឹងអំពីសេចក្តីបង្គាប់អាជ្ញាកណ្តាល ភាគីវិវាទអាចជំទាស់ទៅនឹងសេចក្តីបង្គាប់អាជ្ញាកណ្តាលនេះ។

ចំពោះវិវាទបុគ្គល ភាគីវិវាទអាចជំទាស់នឹងសេចក្តីបង្គាប់អាជ្ញាកណ្តាល ដោយដាក់ពាក្យប្តឹងទៅតុលាការការងារដែលមានសមត្ថកិច្ច។

ចំពោះវិវាទការងាររួម ភាគីវិវាទអាចជំទាស់នឹងសេចក្តីបង្គាប់អាជ្ញាកណ្តាលនៃសវនាការលើកទី១ ដោយៈ

១- ស្នើឲ្យមានការដោះស្រាយដោយក្រុមអាជ្ញាកណ្តាលនៃសវនាការលើកទី២ ដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់នេះ ឬ

២- ប្តឹងទៅតុលាការការងារដែលមានសមត្ថកិច្ច។

សេចក្តីបង្គាប់នៃសវនាការលើកទី២ ជាសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ដែលភាគីវិវាទត្រូវអនុវត្តតាម។

កថាខណ្ឌទី១នៃមាត្រានេះមិនអាចយកមកអនុវត្តបានទេ ក្នុងករណីដែលភាគីទាំងឡាយនៃវិវាទបានឯកភាពគ្នាជាលាយលក្ខណ៍អក្សរ មុនពេលជូនដំណឹងអំពីសេចក្តីបង្គាប់អាជ្ញាកណ្តាល ឬក្នុងករណីដែលភាគីវិវាទបានជាប់កាតព្វកិច្ចអនុវត្តតាមអនុសញ្ញារួម ដែលចែងអំពីការមិនជំទាស់ទៅនឹងសេចក្តីបង្គាប់អាជ្ញាកណ្តាលណាមួយ។

សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលគ្មានភាគីវិវាទណាប្តឹងជំទាស់ទេក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវចាត់ចូលជាស្ថាពរ ហើយអាចយកទៅអនុវត្តបានភ្លាម ដោយភាគីវិវាទដែលមានកាតព្វកិច្ចត្រូវអនុវត្តតាមសេចក្តីបង្គាប់ដែលបានចូលជាស្ថាពរនេះ។ សេចក្តីបង្គាប់អាជ្ញាកណ្តាលមិនអាចអនុវត្តបានឡើយ ក្នុងអំឡុងពេលដែលភាគីណាមួយនៃវិវាទបានដាក់ពាក្យជំទាស់។

ដំណោះស្រាយរបស់អាជ្ញាកណ្តាលលើវិវាទការងាររួមដែលអាចយកទៅអនុវត្តបានហើយ ត្រូវតម្កល់ទុកនិងចុះបញ្ជីទៅតាមបែបបទដូចគ្នានឹងអនុសញ្ញារួមដែរ។

**មាត្រា៣៥ .-**

សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលដោះស្រាយវិវាទអំពីផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធភាពអនុវត្តរយៈពេល១(មួយ)ឆ្នាំ ចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ។

សេចក្តីបង្គាប់នៅតែមានប្រសិទ្ធភាពអនុវត្តដដែលបន្ទាប់ពីរយៈពេល១(មួយ)ឆ្នាំនេះ បើភាគីណាមួយមិនបានជូនដំណឹង ៣(បី)ខែមុនទៅភាគីម្ខាងទៀតថាខ្លួនមិនចង់អនុវត្តតាមសេចក្តីបង្គាប់នោះទៀតទេ។

នៅពេលដែលសេចក្តីបង្គាប់អាជ្ញាកណ្តាលដែលជំនួសអនុសញ្ញារួមក្លាយជាស្ថាពរ សេចក្តីបង្គាប់នេះត្រូវរក្សាទុកជាឯកសារនិងចុះបញ្ជីស្របទៅតាមនីតិវិធីស្តីពីការចុះបញ្ជីអនុសញ្ញារួម។

**មាត្រា៣៦ .-**

ប្រសិនបើរយៈពេលជំទាស់បានផុត ហើយភាគីមួយបដិសេធការអនុវត្តតាមសេចក្តីបង្គាប់ ភាគីម្ខាងទៀតអាចស្នើឲ្យតុលាការការងារនៃសាលាដំបូងទទួលស្គាល់ និងអនុវត្តសេចក្តីបង្គាប់នោះបាន។ ភាគីដែលបានស្នើសុំឲ្យទទួលស្គាល់ និងដែលស្នើសុំឲ្យមានការអនុវត្តសេចក្តីបង្គាប់ត្រូវផ្តល់ជូនតុលាការនូវសេចក្តីបង្គាប់ច្បាប់ចម្លងដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន១(មួយ)ច្បាប់។

ភាគីមួយអាចជៀសវាងការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តសេចក្តីបង្គាប់ជាស្ថាពរ និងដែលចងកាតព្វកិច្ច តែក្នុងករណីភាគីនោះផ្តល់ជូនតុលាការការងារនៃសាលាដំបូងនូវភស្តុតាងបញ្ជាក់ថា សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានភាពត្រឹមត្រូវ ដោយសារៈ

ក- ភាគីវិវាទនោះមិនបានចូលរួមត្រឹមត្រូវក្នុងការជ្រើសរើសអាជ្ញាកណ្តាល ឬមិនបានទទួលនូវការជូនដំណឹងត្រឹមត្រូវអំពីដំណើរការអាជ្ញាកណ្តាល ឬត្រូវបានរារាំងយ៉ាងអយុត្តិធម៌មិនឲ្យធ្វើការបកស្រាយឲ្យបានក្បោះក្បាយអំពីរឿងក្តីរបស់ខ្លួន។

ខ- ការមិនអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់និងបទដ្ឋានការងារ ទាក់ទងនឹងការចេញសេចក្តីបង្គាប់។

គ- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ដែលហួសពីអំណាចដែលប្រគល់ឲ្យដោយច្បាប់និងបទដ្ឋានការងារ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី៥
## ការជំនុំជម្រះបណ្តឹងការងារដោយតុលាការការងារ

**មាត្រា៣៧ .-**

រាល់បណ្តឹងការងារត្រូវប្តឹងទៅតុលាការការងារដែលមានសមត្ថកិច្ច និងជំនុំជម្រះ ដោយអនុវត្តតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

## ជំពូកទី៦
## វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ

**មាត្រា៣៨ .-**

បុគ្គលដែលព្យាយាមដោយទុច្ចរិតក្នុងការធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី ៥ ០០០ ០០០ (ប្រាំលាន) រៀល។

**មាត្រា៣៩ .-**

និយោជកដែលល្មើសនឹងកថាខណ្ឌទី២នៃមាត្រា៥នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី ៥ ០០០ ០០០ (ប្រាំលាន) រៀល។

**មាត្រា៤០ .-**

បុគ្គលណាដែលល្មើសនឹងមាត្រា៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី ៥ ០០០ ០០០ (ប្រាំលាន) រៀល។

**មាត្រា៤១ .-**

នៅគ្រប់ដំណើរការនីតិវិធីដោះស្រាយវិវាទការងារក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ភាគីវិវាទដែលមិនព្រមបង្ហាញខ្លួន តាមការអញ្ជើញរបស់ មន្ត្រីផ្សះផ្សា ឬក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមិនមានមូលហេតុសមស្រប ត្រូវពិន័យជាប្រាក់មិនលើសពី ១០ ០០០ ០០០ (ដប់លាន) រៀល។

**មាត្រា៤២ .-**

បុគ្គលដែលព្យាយាមរារាំងដល់ការអនុវត្តដំណើរការនីតិវិធីដោះស្រាយវិវាទការងារនៅគ្រប់លំដាប់ថ្នាក់ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី ១០ ០០០ ០០០ (ដប់លាន) រៀល។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៤៣ .-**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលមានស្រាប់ ត្រូវបន្តការងាររបស់ខ្លួនរហូតដល់មានការកំណត់ជាថ្មីដោយអនុលោមតាមច្បាប់នេះ។

បណ្តឹងការងារត្រូវដាក់ឲ្យជំនុំជម្រះដោយតុលាការរដ្ឋប្បវេណី រហូតដល់មានការដាក់ឲ្យដំណើរការតុលាការការងារដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៤៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៥ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១៧
នាសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៥។
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**